Australian Government | ParentsNext

# ការរាយការណ៍ អំពីការវិវត្តរបស់អ្នក



នៅពេលចូលរួមក្នុងសេវា ParentsNext អ្នកអាចត្រូវការរាយការណ៍ពីសកម្មភាពរបស់អ្នក។

ទីប្រឹក្សាសេវា ParentsNext របស់អ្នកនឹងប្រាប់អ្នកពីអ្វីដែលត្រូវរាយការណ៍ និងថ្ងៃរាយការណ៍របស់អ្នក។

អ្នកនឹងត្រូវបានស្នើសុំឱ្យ **រាយការណ៍ដោយទៀតទៅ** Centrelink **និងសេវា** ParentsNext - អ្នកអាចរាយការណ៍តាមទូរស័ព្ទ ឬក៏តាមអនឡាញ។

### សារៈសំខាន់

ដើម្បីបន្តទទួលប្រាក់ឧបត្ថម្ភមាតាបិតា ជាការសំខាន់ ត្រូវរាយការណ៍នៅថ្ងៃដែលបានបញ្ជាក់ដោយទីប្រឹក្សារបស់អ្នក។ ប្រសិនបើអ្នកមិនរាយការណ៍ទេ នឹងមានការប៉ះពាល់ដល់ប្រាក់ឧបត្ថម្ភរបស់អ្នក។

ប្រសិនបើមានអ្វីកើតឡើង ហើយអ្នកមិនអាចរាយការណ៍នៅថ្ងៃរាយការណ៍បានទេ សូមប្រាប់ទីប្រឹក្សារបស់អ្នកឱ្យបានឆាប់ ដែលអាចធ្វើទៅបាន ដើម្បីជៀសវាងផលប៉ះពាល់ដល់ប្រាក់ឧបត្ថម្ភរបស់អ្នក។ អ្នកក៏អាចត្រូវការពិភាក្សាជាមួយ Centrelink ដែរ។

## ការរាយការណ៍តាមអនឡាញ

អ្នកអាចរាយការណ៍ទៅ Centrelink តាមរយៈ **វិបសាយថ៍ myGov** ឬក៏កម្មវិធីទូរស័ព្ទដៃ Express Plus Centrelink។ អ្នកក៏អាចរាយការណ៍ទៅសេវា ParentsNext បានដែរ តាមរយៈកម្មវិធី Job Seeker។

ទីប្រឹក្សារបស់អ្នកអាចជួយអ្នក **ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបង្កើតគណនី** myGov account ឬក៏ភ្ជាប់កម្មវិធីទៅនឹងគណនី myGov របស់អ្នក។

### ការរាយការណ៍ទៅ Centrelink

**រាយការណ៍ប្រាក់ចំណូលរបស់អ្នក** និង **បញ្ជាក់ថាអ្នកបានឆ្លើយតបនឹងតម្រូវការ** នៅក្នុងផែនការរបស់អ្នក។

### ការរាយការណ៍ទៅសេវា ParentsNext

**បញ្ជាក់ថាអ្នកបានចូលរួម** សកម្មភាពនៅក្នុងផែនការចូលរួមរបស់អ្នក។

## ចំណុចគន្លឹះសម្រាប់រាយការណ៍សកម្មភាពទៅសេវា ParentsNext

**ប្រសិនបើអ្នកមិនអាចរាយការណ៍តាមអនឡាញ** បានទេ អ្នកអាចហៅទូរស័ព្ទទៅទីប្រឹក្សារបស់អ្នក នៅថ្ងៃរាយការណ៍របស់អ្នក ហើយពួកគេនឹងជួយអ្នកដើម្បីរាយការណ៍។

**អ្នកអាចចូលទៅគណនីដើម្បីទទួលបានការរំលឹកតាមសារខ្លី** តាមរយៈ **កម្មវិធី** Job Seeker ឬតាមអ៊ីម៉េល។ សុំព័ត៌មានបន្ថែមពីទីប្រឹក្សារបស់អ្នក។

**អ្នកអាចដាក់បន្ថែមការប្តូរផ្តាច់ក្នុងគ្រួសាររបស់អ្នក** នៅក្នុងប្រតិទិន នៅក្នុង **កម្មវិធី** Job Seeker ឬក៏ប្រាប់ទីប្រឹក្សារបស់អ្នក ដើម្បីឱ្យពួកគេអាចរៀបចំសកម្មភាពដែលសមស្របនឹងជីវភាពគ្រួសាររបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ dese.gov.au/parentsnext